**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ: មេធាវីការពារក្តីរបស់ យឹម ទិត្យ

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០១៦

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 29-Jul-2016, 14:27
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ: **សាធារណៈ**/Public

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងសារណាដែលបានដាក់ជូនដោយ *អ្នកមិនមែនជាភាគី* អនុលោមតាមឯកសារ D306**

---

**ដាក់ដោយ៖**

**សហមេធាវី**

សូ មូស្សេទ្ធី
Suzana TOMANOVIĆ

**ផ្ញើជូន៖**

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

**សហព្រះរាជអាជ្ញា៖**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តី អ៊ឹម ចែម**

ប៊ិត ស៊ាងលីម

**សហមេធាវីការពារក្តី អោ អាន**

មុំ លុយ្យ
Göran SLUITER
Richard ROGERS

**សហមេធាវីការពារក្តី មាស មុត**

អាង ឧត្តម
Michael G. KARNAVAS

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ក្នុងសំណុំរឿង ០០៤**

លោក យឹម ទិត្យ តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") សូមដាក់ចម្លើយតបរួមដូចខាងក្រោមទៅនឹងសារណាដែលបានដាក់ជូនដោយ *អ្នកមិនមែនជាភាគីនៃរឿងក្តី* ("សារណាអ្នកមិនមែនជាភាគី") អនុលោមតាម*សេចក្តីអំពាវនាវសុំឲ្យដាក់សារណាពីភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ និងអ្នកដែលមិនមែនជាភាគី* ("សំណើសុំ")[1] និងវិធាន ៣៣(២) នៃវិធានផ្ទៃក្នុង ("វិធានផ្ទៃក្នុង") នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")។ មេធាវីការពារក្តីស្នើសុំដាក់ចម្លើយតបនេះជាភាសាអង់គ្លេសសិន ដោយសំណៅបកប្រែជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយដើម្បីគោរពតាមកាលបរិច្ឆេទកំណត់ក្នុងការដាក់ចម្លើយតបដូចបានកំណត់នៅក្នុងសំណើសុំ[2]។

## I. សាវតារនីតិវិធី

1. នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដាក់សំណើសុំឲ្យដាក់សារណា និង*សារណាអ្នកមិនមែនជាភាគី*ស្តីពីបញ្ហាចោទថាតើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលចូលជាធរមាននៅចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ("អំឡុងពេលពាក់ព័ន្ធ") ការវាយប្រហាររបស់រដ្ឋ ឬ អង្គការទៅលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់*ខ្លួន*អាច ឬ ក៏មិនអាចជាការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិលបើយោងតាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ("បញ្ហាចោទ")[3]។ នៅក្នុងសំណើសុំនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានជូនដំណឹងដល់ភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ អំពីសិទ្ធិរបស់ពួកគេក្នុងការដាក់ចម្លើយតបរួមទៅនឹងសារណាដែលដាក់ជូនដោយ*អ្នកដែលមិនមែនជាភាគី*[4]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ជាក់ច្បាស់ថា គាត់នឹងមិនអនុញ្ញាតឲ្យដាក់ចម្លើយតបទៅនឹងសារណាដែលភាគីភាគីផ្សេងទៀតបានដាក់នោះឡើយ[5]។

---

[1] *សេចក្តីអំពាវនាវសុំឲ្យដាក់សារណាពីភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ និង អ្នកដែលមិនមែនជាភាគី* ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ២០១៦, ឯកសារ D306, កថាខណ្ឌ ១៣។

[2] សំណើសុំ, កថាខណ្ឌ ១៣។ សូមមើលសារអេឡិចត្រូនិកពីអង្គភាពបកប្រែភាសាផ្ញើជូនមេធាវីការពារក្តី "ការបកប្រែញត្តិ" ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៦។

[3] សំណើសុំ, កថាខណ្ឌ ៣។

[4] សំណើសុំ, កថាខណ្ឌ ១៣។

[5] សំណើសុំ, កថាខណ្ឌ ១៤។

2. នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០១៦ មេធាវីការពារក្ដីបានដាក់*សារណារបស់ យឹម ទិត្យ ស្ដីពីការបកស្រាយវាក្យស័ព្ទ"ប្រជាជនស៊ីវិល"តាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក* ("សារណា")[6]។

3. នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០១៦ សារណាទាំងនេះក៏ត្រូវបានដាក់ដើម្បីឆ្លើយតបទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ[7] សហមេធាវីការពារក្ដីលោក មាស មុត[8] និងសហមេធាវីការពារក្ដីលោក អោ អាន ផងដែរ[9]។

4. *សារណារបស់អ្នកដែលមិនមែនជាភាគី*សរុបបន្ថែមចំនួន១១("សារណាអ្នកមិនមែនជាភាគី")បានដាក់ដោយអ្នកសិក្សាស្រាវជ្រាវ តំណាងសាកលវិទ្យាល័យច្បាប់ អ្នកជំនាញផ្នែកច្បាប់ និងភាគីផ្សេងទៀតដែលមានការចាប់អារម្មណ៍ ពោលគឺ Ben Saul ('ឯកសារ D306/4')[10] Catherine Drummond, Philippa Webb, Dapo Akande ('ឯកសារ D306/5')[11] Track Impunity Always ('ឯកសារ D306/6')[12] Darryl Robinson ('ឯកសារ D306/7')[13] Ido Rosenzweig

---

[6] សារណារបស់ យឹម ទិត្យ ស្ដីពីការបកស្រាយវាក្យស័ព្ទ "ប្រជាជនស៊ីវិល" តាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក, ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦, ឯកសារ D306/1។

[7] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្ដីអំពាវនាវឲ្យដាក់សារណារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*, ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦, ឯកសារ D306/2។

[8] សំណុំរឿង ០០៣ *សារណារបស់ មាស មុត ស្ដីពីសំណួរថាតើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ១៩៧៥-១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬ អង្គការទៅលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនអាចជាការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិលតាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ឬ យ៉ាងណា*, ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦, ឯកសារ D191/2។

[9] *សារណារបស់ អោ អាន ស្ដីពីបញ្ហាថាតើការវាយប្រហារដោយរដ្ឋ ឬ ដោយអង្គការទៅលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួនអាចត្រូវចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរឬយ៉ាងណា តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ១៩៧៥-១៩៧៩*, ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦, ឯកសារ D306/3។

[10] *សារណាមិនមែនជាភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ - សាស្ត្រាចារ្យ BEN SAUL* ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦, ឯកសារ D306/4។

[11] *សារណាមិនមែនជាភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤*, ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦, ឯកសារ D306/5។

[12] *សារណាមិនមែនជាភាគី*, ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ឯកសារ, D306/6។

[13] *សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្ដី សាស្ត្រាចារ្យ Robinson, deGuzman, Jalloh និង Cryer ស្ដីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (សំណុំរឿង ០០៣ និង ០០៤)*, ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦, ឯកសារ D306/7។

(‘ឯកសារ D306/8’)[14] Joanna Nicholson (‘ឯកសារ D306/9’)[15] Nicholas Tsagourias (‘ឯកសារ D306/10’)[16] Oliver Windridge (‘ឯកសារ D306/11’)[17] Sarah Williams and Rosemary Grey (‘ឯកសារ D306/12’)[18] មជ្ឈមណ្ឌលផ្នែកនីតិអន្តរជាតិ និងនីតិប្រៀបធៀប (Center for International and Comparative Law), សាកលវិទ្យាល័យនីតិសាស្ត្រ Baltimore (University of Baltimore School of law) (‘ឯកសារ D306/13’)[19] និងមជ្ឈមណ្ឌលសិទ្ធិមនុស្ស Belfast នៃសាកលវិទ្យាល័យឃ្វីន (Queen’s University Belfast Human Rights Centre) (‘ឯកសារ D306/14’)[20]។

5. នៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០១៥ ភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ បានទទួលសេចក្ដីបញ្ជាក់បំភ្លឺពីការិយាល័យសហចៅក្រមស៊ើបអង្កេតថា ភាគីមានរយៈពេល ១៥ ថ្ងៃ ក្នុងការដាក់

---

[14] *សារណារបស់ Ido Rosenzweig ដែលមិនមែនជាភាគីស្ដីពីបញ្ហាចោទថាតើតាមច្បាប់ទម្លាប់អន្តរជាតិដែលចូលជាធរមាននៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ការវាយប្រហាររបស់រដ្ឋ ឬ អង្គការមកលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួនអាច ឬក៏មិនអាចជាការវាយប្រហារដែលសំដៅលើ “ប្រជាជនស៊ីវិល” តាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)*,គ្មានកាលបរិច្ឆេទ, ឯកសារ D306/8។

[15] *សារណារបស់បណ្ឌិត Joanna Nicholson ក្នុងនាមជាអ្នកមិនមែនជាភាគី មិនគាំទ្រភាគីណាដើម្បីប្រយោជន៍អ្នកមិនមែនជាភាគី,* ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៦, ឯកសារ D306/9។

[16] *អ្នកមិនមែនជាភាគីផ្ញើជូនសហចៅក្រមស៊ើបអង្កេតអន្តរជាតិ,* ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦, ឯកសារ D306/10។

[17] *សារណាមិនមែនជាភាគីឆ្លើយតបទៅនឹងសេចក្ដីអំពាវនាវឲ្យដាក់សារណាពីភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ និងអ្នកដែលមិនមែនជាភាគី* ,គ្មានកាលបរិច្ឆេទ, ឯកសារ D306/11។

[18] *សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដីដែលដាក់ជូនដោយបណ្ឌិត WILLIAMS និង GREY ក្នុងការឆ្លើយតបទៅនឹងការអំពាវនាវឲ្យដាក់សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្ដីក្នុងសំណុំរឿង ០០៣ និង ០០៤, ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ ២០១៦,* ឯកសារ D306/12។

[19] *សារណាមិនមែនជាភាគីដាក់ដោយមជ្ឈមណ្ឌលច្បាប់អន្តរជាតិ និងច្បាប់ប្រៀបធៀប មហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យ Baltimore ស្ដីពីនីត្យានុកូលភាពនៃការដាក់គោលដៅវាយប្រហារយោធាខ្លួនឯង, ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦,* ឯកសារ D306/13។

[20] *ចម្លើយតបរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សនៃសាកលវិទ្យាល័យ Queen’s University Belfast ទៅនឹង “ការអំពាវនាវឲ្យដាក់សារណាពីភាគីនៃសំណុំរឿង ០០៣ និង ០០៤ និងការអំពាវនាវឲ្យដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី” របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦,* ឯកសារ D306/14។

ចម្លើយតបរួមទៅនឹងសារណា*របស់អ្នកមិនមែនជាភាគី*ដែលខ្លួនបានទទួលដោយគិតរាប់ចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងអំពីសំណៅបកប្រែជាភាសាខ្មែរ[21]។

6. នៅថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០១៦ ភាគីបានទទួលការជូនដំណឹងអំពីសំណៅបកប្រែជាភាសាខ្មែរនៃសារណាទាំងអស់របស់*អ្នកដែលមិនមែនជាភាគី*[22]។

## II. ចម្លើយតប

### ក.សហចៅក្រមស៊ើបអង្កេតមិនត្រូវបកស្រាយឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ("ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ") ដើម្បីបំពេញគោលបំណងសីលធម៌ ឬ មនោគមន៍វិជ្ជានោះទេ

7. សារណាអ្នកមិនមែនជាភាគីមួយចំនួនអះអាងថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបកស្រាយដើម្បីបំពេញតាមគោលបំណងសីលធម៌ ឬ មនោគមន៍វិជ្ជា[23]។ សារណាអ្នកមិនមែនជាភាគីទាំងនេះមានកំហុសដោយសារបានកំណត់និយមន័យនៃពាក្យ "ប្រជាជនស៊ីវិល" ដើម្បីឆ្លុះបញ្ចាំងគោលបំណងនេះពុំមែនស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលពាក់ព័ន្ធនោះឡើយ។

8. ឯកសារ D306/10 អះអាងថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមានគោលបំណងការពារសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និងការពារកុំឱ្យមានការរំលោភធំធេងផ្នែកសិទ្ធិមនុស្សមកលើប្រជាជន[24]។ ឯកសារ D306/11 អះអាងថា សមាជិកនៃកងកម្លាំងប្រដាប់អាវុធគួររួមបញ្ចូលជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិប្រសិនបើពួកគេ "ត្រូវរបបណាមួយដាក់គោលដៅមួយនៃការវាយប្រហារទូទៅ និងជាប្រព័ន្ធដោយមូលហេតុផ្សេងៗ រួមមាន មូលហេតុជាតិពិន្ទុ ឬ សាសនា

---

[21] សូមមើលសារអេឡិចត្រូនិកផ្ញើមកពី ឆាយ ច័ន្ទលីដា ក្នុងនាមសហចៅក្រមស៊ើបអង្កេតអន្តរជាតិ "*ការបញ្ជាក់បំភ្លឺលើឯកសារ D191 នៅក្នុងសំណុំរឿង ០០៣ និងឯកសារ D306 នៅក្នុងសំណុំរឿង ០០៤*", ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០១៦។

[22] សារអេឡិចត្រូនិកអំពីសេចក្តីជូនដំណឹងផ្ញើមកពីមន្ត្រីគ្រប់គ្រងសំណុំរឿង "*ការបកប្រែ៖ សំណុំរឿង ០០៤*", ចុះថ្ងៃទី២៤ ខែ មិថុនា ឆ្នាំ២០១៦។

[23] សូមមើល ឯកសារ D306/8 ឯកសារ D306/10 និងឯកសារ D306/11។

[24] ឯកសារ D306/10, កថាខណ្ឌ ២០។

(ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)" ដោយសារវា "ស្របតាមស្មារតីនៃការបង្កើតឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការអនុវត្តច្បាប់ឧក្រិដ្ឋកម្មនេះរហូតដល់ឆ្នាំ១៩៧៥ ផងដែរ"[25]។

9. ស្រដៀងគ្នានេះដែរ ឯកសារ D306/8 ទទួលស្គាល់ថា "មិនមានយុត្តិសាស្ត្រដែលប្រើប្រាស់ក្របខណ្ឌ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ដើម្បីស៊ើបអង្កេត ឬ ចោទប្រកាន់អំពីការប្រព្រឹត្តឧក្រិដ្ឋកម្មមកលើយុទ្ធជនរបស់ខ្លួនឯងឡើយ" ប៉ុន្តែលើកទឡ្ហីករណ៍តវ៉ាថា "ការមិនមានការអនុវត្តបែបនេះមិនគួរនាំឱ្យមានសេចក្តីសន្និដ្ឋានជាស្វ័យប្រវត្តិថា ក្រុមមនុស្សប្រភេទនេះត្រូវបានដកចេញពីក្របខណ្ឌវិធានការការពារបានឡើយ។ ផ្ទុយមកវិញ ក្រុមមនុស្សប្រភេទនេះត្រូវបញ្ចូលនៅក្នុងក្របខណ្ឌវិធានការការពារ"[26]។ សារណាអ្នកមិនមែនជាភាគីនេះបន្តលើកឡើងទឡ្ហីករណ៍ដែលបានផ្អែកលើ "សីលធម៌" និង "គុណសម្បត្តិ" ក្នុងការរួមបញ្ចូលយុទ្ធជនរបស់រដ្ឋផ្ទាល់ជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

10. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនអាចកំណត់និយមន័យឱ្យបានត្រឹមត្រូវដោយយោងលើគោលបំណងផ្អែកលើសីលធម៌ មនោគមន៍វិជ្ជា ឬ "ស្មារតី" នោះទេ។ ផលប៉ះពាល់នៃការភ្ជាប់គោលបំណងបែបនេះលើបទល្មើសព្រហ្មទណ្ឌ នឹងធ្វើឱ្យនិយមន័យលើបទល្មើសនោះមានភាពស្រពិចស្រពិល និងជាការរំលោភលើគោលការណ៍សច្ចភាពផ្លូវច្បាប់។ ករណីនេះគឺដោយសារនិយមន័យនៃ "ប្រជាជនស៊ីវិល" នឹងសម្របទៅតាមនោះដើម្បីបំពេញគោលបំណងសីលធម៌ ឬ មនោគមន៍វិជ្ជាដែលកំពុងភ្ជាប់ទៅនឹងបទល្មើសនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ឯកសារ D306/10 បង្ហាញនូវករណីនេះដោយបានអះអាងថា "ប្រជាជនស៊ីវិល" រួមបញ្ចូលទាំង "ពលរដ្ឋ" និង "មនុស្សគ្រប់រូបទាំងអស់"[27]។ ទោះបីជាវាអាចសម្រេចគោលបំណងនៃការការពារសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិក៏ដោយ ក៏វាមិនមែនជាការឆ្លុះបញ្ចាំងត្រឹមត្រូវមួយលើនិយមន័យនៃពាក្យ "ប្រជាជនស៊ីវិល" នៅក្នុងអំឡុងពេលពាក់ព័ន្ធនោះផងដែរ។

11. វិធីសាស្ត្រនៃការបកស្រាយទៅតាមគោលបំណងនេះ ក៏រំលោភគោលការណ៍នីត្យានុកូលភាពផងដែរពីព្រោះវាកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយយោងទៅលើអាកប្បកិរិយាសីលធម៌ និងមនោគមន៍វិជ្ជាបច្ចុប្បន្ន។ ឧទាហរណ៍មួយនៃកំហុសនេះឃើញលេចឡើងនៅក្នុង

---

[25] ឯកសារ D306/11 កថាខណ្ឌ ២១។

[26] ឯកសារ D306/8 ទំព័រ ៥។

[27] ឯកសារ D306/10 កថាខណ្ឌ ២០។

ឯកសារ D306/10 ដែលលើកឡើងថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានចងក្រងឡើងដើម្បីសម្រេចនូវគោលបំណងសីលធម៌នៃការការពារក្ដីគ្រប់*មនុស្ស* ទាំងអស់ពីសកម្មភាពរបស់រដ្ឋ[28]។ ដូច Cassese កត់សម្គាល់ រដ្ឋទាំងឡាយដែលបានចូលរួមនៅក្នុងការកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្ដោតលើសលប់ក្នុងការធ្វើយ៉ាងណាធានាថា ឧក្រិដ្ឋកម្មថ្មីៗពុំជ្រៀតជ្រែកលើអធិបតេយ្យរបស់រដ្ឋខ្លួន[29]។ ការបកស្រាយក្នុងលក្ខណៈពន្លាតលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានស្នើឡើងដោយឯកសារ D306/10 ពុំស្របតាមទម្លាប់គតិយុត្តនៃអំឡុងពេលពាក់ព័ន្ធ។ ហេតុដូច្នេះ វារំលោភគោលការណ៍នីត្យានុកូលភាព។

12. សហចៅក្រមស៊ើបអង្កេត(“ស.ច.ស”) មិនត្រូវពិនិត្យមើលលើគោលបំណងសីលធម៌ ឬ មនោគមន៍វិជ្ជាដូចបានលើកឡើងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងការកំណត់និយមន័យលើពាក្យ “ប្រជាជនស៊ីវិល” នោះទេ។ ផ្ទុយមកវិញ ស.ច.ស ត្រូវកំណត់និយមន័យលើពាក្យនេះឱ្យស្របទៅតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ (“ច្បាប់ទំនៀមទម្លាប់អន្តរជាតិ”) ដែលចូលជាធរមាននៅក្នុងអំឡុងពេលពាក់ព័ន្ធនោះ។

## ខ. សហចៅក្រមស៊ើបអង្កេតមិនត្រូវអនុវត្តវិធីសាស្ត្របកស្រាយទៅតាមគោលបំណងចំពោះនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ

13. សារណាអ្នកមិនមែនជាភាគីជាច្រើនអនុវត្តវិធីសាស្ត្របកស្រាយ ទៅតាមគោលបំណងលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយពិនិត្យមើល “គោលបំណង” ដូចដែលបានអះអាងនៅពីក្រោយការវិវឌ្ឍន៍ នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ឧទាហរណ៍ ឯកសារ D306/11 ផ្ដល់ទឡ្ហីករណ៍តវ៉ាថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ “បានបំពេញចន្លោះប្រហោងនេះ និងពង្រឹងឧក្រិដ្ឋកម្មអន្តរជាតិឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់សហគមន៍អន្តរជាតិដើម្បីទប់ស្កាត់របបនានា និងមេដឹកនាំនានាកុំឱ្យគេចចេញពីការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការវាយប្រហារមកលើជនណាម្នាក់”[30]។

---

[28] *ដូចជើងទំព័រខាងលើ* ។

[29] Antonio Cassese and Paola Gaeta, *Cassese's International Criminal Law*, Oxford University Press, ឆ្នាំ ២០១៣, ទំព័រ ៨៦ ។

[30] ឯកសារ D306/11 កថាខណ្ឌ ៨។

14. មាត្រា ៥ នៃច្បាប់ អ.វ.ត.ក កំណត់និយមន័យលើបុគ្គលដែលអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថាជា "ប្រជាជនស៊ីវិល"។ ករណីមានលក្ខណៈច្បាស់លាស់ គ្មានអ្វីស្រពិចស្រពិល ហើយពុំតម្រូវឱ្យងាកទៅស៊ើបអង្កេតលើ "គោលបំណង" ដូចបានអះអាងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះឡើយ។ ម្យ៉ាងវិញទៀត វិធីសាស្ត្របែបនេះបានលើកហេតុផលដោយផ្អែកលើទស្សនៈដែលថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបង្កើតឡើងដោយសហគមន៍អន្តរជាតិរួមមួយនៅក្នុងបរិបទនៃគម្រោងច្បាប់ព្រហ្មទណ្ឌអន្តរជាតិទូលាយ ("ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ")។ ករណីនេះពុំផ្ទុះបញ្ចាំង ថាតើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានវិវឌ្ឍដោយរបៀបណាក្រោយសង្គ្រាមលោកលើកទីពីរ ហើយក៏ពុំបានបង្ហាញឱ្យបានត្រឹមត្រូវអំពីឋានៈនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងឆ្នាំ១៩៧៥នោះដែរ[31]។

15. ដូចបានលើកឡើងនៅក្នុងសារណា ទោះបីជា ស.ច.ស អាចពិនិត្យមើល *បរិបទ*ដែលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានចងក្រងឡើង ដើម្បីជួយជ្រោមជ្រែងនៅក្នុងការបញ្ជាក់លើនិយមន័យរបស់វាក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលពាក់ព័ន្ធក៏ដោយ ក៏ ស.ច.ស មិនគួរព្យាយាមកំណត់លើ "គោលបំណង" នៃការចងក្រងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ[32]។

### គ. សហចៅក្រមស៊ើបអង្កេតមិនត្រូវពិនិត្យមើលរបបគតិយុត្តផ្សេងទៀតដើម្បីកំណត់និយមន័យលើពាក្យ "ប្រជាជនស៊ីវិល" នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ

16. សារណាអ្នកមិនមែនជាភាគីជាច្រើនអនុវត្តពិនិត្យមើលច្បាប់សិទ្ធិមនុស្សអន្តរជាតិ ("ច្បាប់សិទ្ធិមនុស្សអន្តរជាតិ") (International Human Right Law) និងច្បាប់មនុស្សធម៌អន្តរជាតិ ("ច្បាប់មនុស្សធម៌អន្តរជាតិ") (International Humanitarian Law) ដើម្បីកំណត់និយមន័យលើពាក្យ "ប្រជាជនស៊ីវិល"។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្ថិតនៅក្នុងក្របខណ្ឌនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ហើយមិនគួរបកស្រាយដោយយោងលើរបបគតិយុត្តផ្សេងទៀតនោះឡើយ។

17. សារណាអ្នកមិនមែនជាភាគីមួយចំនួនបានសំអាងលើច្បាប់សិទ្ធិមនុស្សអន្តរជាតិក្នុងការអះអាងអំពីនិយមន័យទូលាយនៃពាក្យ "ប្រជាជនស៊ីវិល"។ ឯកសារ D306/6 កត់សម្គាល់ថា ខុសពីច្បាប់មនុស្សធម៌អន្តរជាតិ ច្បាប់សិទ្ធិមនុស្សអន្តរជាតិអនុវត្តទំនាក់ទំនងរវាងបុគ្គល និងរដ្ឋ។ ឯកសារនេះ

---

[31] សារណា, កថាខណ្ឌ ៣។

[32] សារណា, កថាខណ្ឌ ៣-៥។

លើកឡើងថា "ប្រជាជនស៊ីវិល" ត្រូវបកស្រាយដោយរួមបញ្ចូលសមាជិកនៃយោធារបស់រដ្ឋខ្លួនឯងផងដែរ ដោយសារការបកស្រាយដូច្នេះវាស្របជាមួយនឹងអំណាចនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលត្រូវការពារបុគ្គលពីរដ្ឋ[33]។ ចំណែកឯកសារ 306/10 បង្ហាញឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថាជាវិធីសាស្ត្រមួយក្នុងការការពារសិទ្ធិមនុស្ស៖ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិការពារសេចក្តីថ្លៃថ្នូរមនុស្សជាតិ ។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិការពារមនុស្សពីការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ"[34]។

18. ច្បាប់សិទ្ធិមនុស្សអន្តរជាតិគឺជារបបគតិយុត្តមួយពិសេស និងដាច់ដោយឡែកពីច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ ខុសពីតុលាការព្រហ្មទណ្ឌអន្តរជាតិ និងសាលាក្តីនានាផ្សេងទៀត អ.វ.ត.ក ពុំមានយុត្តាធិការលើការបំពារបំពានច្បាប់សិទ្ធិមនុស្សអន្តរជាតិនោះឡើយ។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិអាចយកមកអនុវត្តនៅក្នុងតុលាការ និងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិបានដរាបណាវាអនុវត្តលើការការពារសិទ្ធិមូលដ្ឋាននានា[35]។ ការអនុវត្តនេះមិនពង្រីករហូតដល់ការបកស្រាយលើបទល្មើសលើកលែងតែការបកស្រាយនោះវារំលោភលើសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ដូច្នេះ ច្បាប់សិទ្ធិមនុស្សអន្តរជាតិមិនអាចប្រើប្រាស់ដើម្បីបកស្រាយ "ប្រជាជនស៊ីវិល" ដោយរួមបញ្ចូលទាំងសមាជិកយោធារបស់រដ្ឋខ្លួនឯងនោះឡើយ។

19. ស្រដៀងគ្នានេះដែរ ច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិមានលក្ខណៈដោយឡែកពីគ្នា ប៉ុន្តែគឺជារបបគតិយុត្តពាក់ព័ន្ធគ្នា។ ការបំពារបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិអាចស្ថិតនៅក្រោមវិសាលភាពនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ ជាការពិត អ.វ.ត.ក មានយុត្តាធិការលើការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩[36]។ ក៏ប៉ុន្តែ ទោះបីជាច្បាប់មនុស្សធម៌អន្តរជាតិបានគ្រប់គ្រងជាយូរមកហើយលើទង្វើនៃការប្រទូស្តរ៉ាយនៅក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ និងមិនអន្តរជាតិក៏ដោយ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានលេចចេញជាប្រភេទឧក្រិដ្ឋកម្មថ្មីមួយនៅក្រោយបញ្ចប់សង្គ្រាមលោកលើកទីពីរ។ ដូច Cassese លើកឡើងថា៖

---

[33] ឯកសារ D306/6 កថាខណ្ឌ ៨-៩។

[34] ឯកសារ D306/10 កថាខណ្ឌ ២០។

[35] ឧទាហរណ៍ លក្ខន្តិកៈនៃតុលាការ ICC សាលាក្តី ICTY សាលាក្តី ICTR និងតុលាការ STL ពុំមានបទប្បញ្ញត្តិចែងអំពីការចោទប្រកាន់កាត់ទោសការបំពានលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

[36] មាត្រា ៦ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

វាហាក់ដូចជាគ្មានអ្វីអាចជំទាស់តវ៉ាបានថា កិច្ចព្រមព្រៀងទីក្រុងឡុងដ៍ឆ្នាំ១៩៤៥ ដែលបានបង្កើតសាលាក្តីនូរ៉ឹមប៊ឺកចែងអំពីឧក្រិដ្ឋកម្មថ្មីពីរប្រភេទ៖ ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[37]។

20. ដូច្នេះ ច្បាប់មនុស្សធម៌អន្តរជាតិមិនអាចប្រើប្រាស់ដើម្បីកំណត់និយមន័យ ឬ បំពេញបន្ថែមនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិឡើយ។ អាស្រ័យហេតុនេះ ទោះបីជា ឯកសារ D306/13 កត់សម្គាល់ថា "ក្រោមច្បាប់មនុស្សធម៌អន្តរជាតិ ការវាយប្រហារដោយរដ្ឋ ឬ អង្គការប្រឆាំងនឹងសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនអាចខុសច្បាប់" ក៏វាមិនជួយដល់ការបកស្រាយឱ្យបានត្រឹមត្រូវលើពាក្យ "ប្រជាជនស៊ីវិល" នៅក្រោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះឡើយ[38]។

## ឃ. សមាជិកនៃយោធារបស់រដ្ឋខ្លួនឯងមិនមែនជាជនស៊ីវិលនោះឡើយ

21. ឯកសារ D306/11 អះអាងថា សមាជិកយោធានៃរដ្ឋរបស់ខ្លួនមិនគួរមិនបញ្ចូលជា "ប្រជាជនស៊ីវិល" ដោយសារតែមុខងាររបស់ពួកគេនោះទេ៖ "មិនមានមូលហេតុថា "ប្រជាជនស៊ីវិល" មិនអាចរាប់បញ្ចូលទាំងជនដែលស្ថិតនៅក្នុងកងកម្លាំងប្រដាប់អាវុធឡើយពីព្រោះថាមានគ្រូបង្រៀន ឬ វេជ្ជបណ្ឌិត"[39]។ ករណីនេះស្របជាមួយនឹងសំណើសុំដែលលើកឡើងថា៖

> ហាក់ដូចជាគ្មានការជំទាស់ទេថា របបណាមួយក្នុងគ្រាមានសន្តិភាពបានព្យាយាមបោសសម្អាតកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួន ដូចជា ទាហានដែលមានជាតិពិន្ទុ ឬ ជំនឿណាមួយនោះគឺជារបបដែលបានប្រព្រឹត្តបទល្មើសផ្សេងៗនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់ទម្លាប់អន្តរជាតិពីព្រោះថា លក្ខណៈសម្បត្តិជាយុទ្ធជនរបស់ជនរងគ្រោះដោយសារពួកគាត់ជាទាហាននោះគឺមិនជាប់ពាក់ព័ន្ធទាល់តែសោះនៅក្នុងបរិបទនេះ។...[40]

22. សមាជិកយោធាត្រូវបានចាត់ទុកដោយឡែកពីជនស៊ីវិលទាំងនៅក្នុងពេលសន្តិភាព និងនៅក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធ។ ឧទាហរណ៍មួយច្បាស់លាស់នៃករណីនេះគឺថា ខុសពីគ្រូ

---

[37] Antonio Cassese and Paola Gaeta, *Cassese's International Criminal Law*, Oxford University Press, ឆ្នាំ ២០១៣, ទំព័រ ៣០ ។

[38] ឯកសារ D306/13 ទំព័រ ៣។

[39] ឯកសារ D306/11 ទំព័រ ១៦។

[40] សំណើសុំ កថាខណ្ឌ ៥។

បង្រៀន និងវេជ្ជបណ្ឌិត សមាជិកយោធាស្ថិតនៅក្រោមរបបគតិយុត្តផ្ទាល់របស់ខ្លួន។ ដូច្នេះ សកម្មភាពរបស់ពួកគេត្រូវបានគ្រប់គ្រងដោយច្បាប់យោធាដែលជារឿយៗខុសពីច្បាប់ព្រហ្មទណ្ឌក្នុងស្រុក។

23. ម្យ៉ាងវិញទៀត សមាជិកយោធានឹងមិនបាត់បង់ឋានៈរបស់ពួកគេដោយស្វ័យប្រវត្តិនៅក្នុងពេលសង្គ្រាមនោះទេលើកលែងតែពួកគេត្រូវបានអនុញ្ញាតឲ្យឈប់ពីកាតព្វកិច្ចយោធា។ ករណីនេះគឺរបៀបដែលរដ្ឋមានលទ្ធភាពគ្រប់គ្រងកងទ័ពអចិន្ត្រៃយ៍នៅក្នុងពេលសន្តិភាព។ សមាជិកកងទ័ពដែលចាកចេញពីការបំពេញកាតព្វកិច្ចយោធានៅមុនពេលបញ្ចប់កាតព្វកិច្ចរបស់ខ្លួន និងនៅមុនពេលអនុញ្ញាតឲ្យចាកចេញជាទូទៅបានប្រព្រឹត្តនូវបទល្មើសមួយ។ បទល្មើសនានាទាក់ទងនឹងអវត្តមានពីការបំពេញកាតព្វកិច្ចមិនកម្រិតត្រឹមជម្លោះប្រដាប់អាវុធ និងអាចប្រព្រឹត្តឡើងនៅក្នុងពេលសង្គ្រាម និងសន្តិភាព។ ករណីនេះបង្ហាញច្បាស់តាមរយៈក្រមស្តីពីយោធាកម្ពុជាឆ្នាំ១៩៥៤ ដែលរួមបញ្ចូលទាំងបទល្មើសនៃ "អវត្តមានគ្មានច្បាប់" (មាត្រា ១៦២) និង "ការបោះបង់ចោលជួរ" (មាត្រា ១៦៧)។ បទល្មើសនានាអាចប្រព្រឹត្តឡើងក្នុងពេលសន្តិភាពជាមួយនឹងការប្រព្រឹត្តនៅក្នុងអំឡុងពេលសន្តិភាពដែលចាត់ទុកជាស្ថានទម្ងន់[41]។

24. ឯកសារ D306/6 ស្នើឡើងថា យោធានៃរដ្ឋខ្លួនឯងនឹងខ្វះនូវការការពារដ៏ប្រសិទ្ធភាពមួយចំពោះរដ្ឋរបស់ពួកគេ ដូច្នេះ ពួកគេគួរត្រូវចាត់ទុកជា ក). ជនស៊ីវិល[42] ឬ ខ). *អ្នកបោះបង់ចោលការប្រយុទ្ធ*[43]។ ទឡ្ហីករណ៍ទាំងនេះបានអនុវត្តទស្សនទាននៃច្បាប់មនុស្សធម៌អន្តរជាតិមិនត្រឹមត្រូវដើម្បីកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

25. ទឡ្ហីករណ៍ទីមួយ ស្នើសុំឲ្យសំអាងលើទស្សនទានក្រោមច្បាប់មនុស្សធម៌អន្តរជាតិលើការកំណត់គោលដៅ។ ទឡ្ហីករណ៍នេះលើកឡើងថា "ជនស៊ីវិលទទួលបានការការពារដរាបណាពួកគេពុំចូលរួមសកម្មនៅក្នុងការប្រទូសរ៉ាយ" ហើយបានយោងលើមាត្រា ៤ នៃអនុសញ្ញាទីក្រុងហ្សឺណែវលើកទីIV[44]។

---

[41] មាត្រា ១៦២, មាត្រា ១៦៤ និងមាត្រា ១៦៧ នៃក្រមស្តីពីយោធាកម្ពុជា។

[42] ឯកសារ D306/6 កថាខណ្ឌ ១៤-១៧។

[43] ឯកសារ D306/6 កថាខណ្ឌ ១៨-២០។

[44] ឯកសារ D306/6 កថាខណ្ឌ ១៤។

26. ការកំណត់គោលដៅ គឺជាវិធានទំនៀមទម្លាប់មនុស្សធម៌អន្តរជាតិមួយដែលទាក់ទងនឹងការជ្រើសរើសគោលដៅស្របច្បាប់នៅពេលចាប់ផ្តើមការវាយប្រហារ[45]។ ទោះបីជាមាត្រា ៤ នៃអនុសញ្ញាទីក្រុងហ្សឺណែវលើកទីIV កំណត់និយមន័យទស្សនទាននៃ "បុគ្គលត្រូវបានការពារ" ហើយលើកឡើងថា ការការពារនេះពុំអនុវត្តលើពលរដ្ឋនៃរដ្ឋរបស់ខ្លួនផ្ទាល់៖

> បុគ្គលការពារដោយអនុសញ្ញាគឺជាបុគ្គលដែល ទោះក្នុងពេលណាមួយ ឬ ក្នុងស្ថានភាពណាមួយក៏ដោយ យល់ឃើញថា នៅក្នុងពេលជម្លោះ ឬ នៅក្នុងមុខងាររបស់ពួកគេ ពួកគេស្ថិតនៅក្នុងដៃរបស់ភាគីជម្លោះ ឬ មហាអំណាចកាន់កាប់ដែលពួកគេមិនមែនជាពលរដ្ឋ។
>
> ពលរដ្ឋនៃរដ្ឋមួយដែលពុំមានកាតព្វកិច្ចគោរពលើអនុសញ្ញាមិនទទួលបានការការពារដោយអនុសញ្ញានេះទេ។ ពលរដ្ឋនៃរដ្ឋអព្យាក្រឹតមួយដែលយល់ឃើញថា ពួកគេនៅក្នុងទឹកដីនៃរដ្ឋជាគូសត្រូវ និងពលរដ្ឋនៃរដ្ឋជាសហគូសត្រូវមិនត្រូវបានចាត់ទុកជាបុគ្គលទទួលបានការការពារនោះទេទោះបីជារដ្ឋដែលខ្លួនជាពលរដ្ឋមានតំណាងទូតធម្មតានៅក្នុងរដ្ឋដែលពួកគេធ្លាក់ក្នុងកណ្តាប់ដៃក៏ដោយ[46]។

27. ដូច្នេះ ទឡ្ហីករណ៍នេះច្រឡំបញ្ចូលគោលការណ៍ច្បាប់មនុស្សធម៌ពីរដោយឡែកពីគ្នា។ គ្មានគោលការណ៍ណាមួយជួយជ្រោមជ្រែង នៅក្នុងការកំណត់ថាតើហេតុអ្វីសមាជិកយោធានៃរដ្ឋរបស់ខ្លួនគួរត្រូវបានចាត់ទុកជាជនស៊ីវិល។

28. ទឡ្ហីករណ៍ទីពីរនៅក្នុងឯកសារ D306/6 ស្នើឡើងថា ការខ្វះនូវការពារពារដ៏ប្រសិទ្ធភាពធ្វើឱ្យសមាជិកយោធានៃរដ្ឋខ្លួនឯងក្លាយជា*អ្នកបោះបង់ចោលការប្រយុទ្ធ* (*hors de combat*)[47]។ ពាក្យនេះមានអត្ថន័យច្បាស់លាស់ ហើយយុទ្ធជន*ដែលបោះបង់ចោលការប្រយុទ្ធ*(*hors de combat*)ពុំមែនជាជនស៊ីវិលនោះទេយោងតាមគោលបំណងនៃច្បាប់មនុស្សធម៌អន្តរជាតិ[48]។ អាស្រ័យហេតុ

---

[45] ICRC, មូលដ្ឋានទិន្នន័យនៃច្បាប់ទំនៀមទម្លាប់មនុស្សធម៌អន្តរជាតិ វិធាន ២១ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ អាចរកមើលបាននៅត្រង់ https://www.icrc.org/customary-ihl/eng/docs/v1_rul_rule21។

[46] មាត្រា ៤ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV។

[47] ឯកសារ D306/6 កថាខណ្ឌ ១៦។

[48] សាលាក្តី ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Matić* អង្គជំនុំជម្រះសាលាដំបូង សាលក្រម ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ IT-95-11-T កថាខណ្ឌ៥៦។ ដូចបានបញ្ជាក់នៅក្នុងសាលាក្តី ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Matić* អង្គជំនុំជម្រះតុលាការកំពូល សាលដីកា ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៨ IT-95-11-A កថាខណ្ឌ៣០២។

នេះ គោលការណ៍នេះពុំជួយជ្រោមជ្រែងនៅក្នុងការអះអាងថា សមាជិកយោធានៃរដ្ឋខ្លួនឯងអាច ឬ គួរចាត់ទុកជាជនស៊ីវិលយោងតាមគោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

29. ឯកសារ D306/7 ស្នើឡើងស្រដៀងគ្នាថា ការវាយប្រហារប្រឆាំងនឹងយោធានៃរដ្ឋខ្លួនឯងអាចចាត់ទុកជាការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិល ឯកសារនេះលើកឡើងដូច្នេះមែនក៏ប៉ុន្តែបានធ្វើការបែងចែករវាងវិធីសាស្ត្រនៃ "គោលដៅស្របច្បាប់" និងវិធីសាស្ត្រ "ផ្អែកលើឋានៈ" [49]។ ឯកសារនេះអះអាងថា "យោងតាមវិធីសាស្ត្រ "ផ្អែកលើគោលដៅស្របច្បាប់" ដ៏ត្រឹមត្រូវ "ជនស៊ីវិល" ត្រូវបានបកស្រាយស្របតាមគោលការណ៍នៃការបែងចែក"[50]។

30. គោលការណ៍នេះការបែងចែកជាទូទៅត្រូវបានចងក្រងនៅក្នុងពាក្យពេចន៍ទាំងនេះ៖

> ភាគីជម្លោះត្រូវបែងចែកនៅគ្រប់ពេលទាំងអស់រវាងជនស៊ីវិល និងយុទ្ធជន។ ការវាយប្រហារអាចសំដៅតែចំពោះយុទ្ធជនប៉ុណ្ណោះ។ ការវាយប្រហារមិនត្រូវសំដៅប្រឆាំងនឹងជនស៊ីវិលនោះទេ[51]។

31. គោលការណ៍នេះទាក់ទងនឹងការជ្រើសរើសគោលដៅស្របច្បាប់នៅក្នុងអំឡុងពេលវាយប្រហារ។ វាពុំបានជួយជ្រោមជ្រែងនៅក្នុងការបញ្ជាក់និយមន័យត្រឹមត្រូវលើពាក្យ "ប្រជាជនស៊ីវិល" នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងអំឡុងពេលពាក់ព័ន្ធនោះទេ។

## ខ. ការបែងចែករវាងបទល្មើស "ប្រភេទមនុស្សឃាត" និង "ប្រភេទធ្វើទុក្ខបុកម្នេញ" ពុំមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលពាក់ព័ន្ធនោះឡើយ

32. សារណាអ្នកមិនមែនជាភាគីមួយចំនួនតវ៉ាថា វាមានការបែងចែករវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ "ប្រភេទមនុស្សឃាត" និង "ប្រភេទធ្វើទុក្ខបុកម្នេញ"[52]។ ទឡ្ហីករណ៍នេះត្រូវបានការពារយ៉ាង

---

[49] ឯកសារ D306/7 កថាខណ្ឌ ៣។

[50] *ដូចជើងទំព័រខាងលើ ។*

[51] ICRC, មូលដ្ឋានទិន្នន័យនៃច្បាប់ទំនៀមទម្លាប់មនុស្សធម៌អន្តរជាតិ វិធាន ២១ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ អាចរកមើលបាននៅត្រង់ ://www.icrc.org/customary-ihl/eng/docs/v1_cha_chapter1_rule1.។

[52] សូមមើលឧទាហរណ៍ឯកសារ D306/5 កថាខណ្ឌ ១៣។

ខ្លាំងក្លាដោយ Cassese[53] ហើយបានសំអាងលើការបកស្រាយនៃមាត្រា ៦(គ) នៅក្នុងធម្មនុញ្ញនៃសាលាក្តីយោធាអន្តរជាតិ៖

> ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពោលគឺ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឱ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងទៀតដែលត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងជនស៊ីវិលនៅមុនពេល ឬ នៅក្នុងអំឡុងពេលសង្គ្រាម ឬ ការធ្វើទុក្ខម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា នៅក្នុងពេលប្រព្រឹត្ត ឬ ដែលជាប់ទាក់ទងនឹងឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការនៃសាលាក្តី មិនថាបាន ឬ មិនបានរំលោភលើច្បាប់ក្នុងស្រុកនៃប្រទេសដែលឧក្រិដ្ឋកម្មបានប្រព្រឹត្តនោះទេ[54]។

33. ការបកស្រាយដោយបញ្ចូលពាក្យ "ឬ" នៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនត្រូវបានគាំទ្រដោយការអនុវត្តរបស់រដ្ឋនៅក្នុងអំឡុងពេលពាក់ព័ន្ធនោះទេ ហើយវាក៏ពុំបានទទួលស្គាល់ដោយអ្នកសិក្សាស្រាវជ្រាវល្បីៗផងដែរ។ ដូច Schwelb កត់សម្គាល់៖

> នៅក្នុងការបកស្រាយអត្ថបទ វិមតិសង្ស័យអាចលេចឡើងទាក់ទងនឹងករណីថាតើការកំណត់ត្រឹមប្រជាជនស៊ីវិលអនុវត្តផងដែរលើអំពើនានាដែលចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយសារវាមិនស្ថិតនៅក្នុងប្រភេទនៃប្រភេទមនុស្សឃាតដូចបានចែងរៀបរាប់នៅក្នុងនោះ។ បើពិនិត្យមើលទៅ វាហាក់ដូចជាបង្ហាញថា "ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា" គឺជាអំពើបែបនេះ។ ដូច្នេះ វាគេអាចនៅតែលើកឡើងថា ការធ្វើទុក្ខបុកម្នេញដែលវាដោយឡែកពីឧក្រិដ្ឋកម្មនៃប្រភេទមនុស្សឃាតអាចត្រូវបានប្រព្រឹត្តដោយអំពើសំដៅប្រឆាំងនឹងសមាជិកកងកម្លាំងប្រដាប់អាវុធ។ ដូច្នេះ វាមានការសង្ស័យថាតើការបែកចែកឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៅជាឧក្រិដ្ឋកម្មប្រភេទមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា អាចនៅតែមានដដែលនៅពេលពិនិត្យមើលពិធីសារទីក្រុងប៉ែកឡាំងចុះថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៤៥[55]។

34. ម្យ៉ាងវិញទៀត ករណីនេះមិនផ្ទុះបញ្ជាំងការបកស្រាយមាត្រា ៥ នៃច្បាប់ អ.វ.ត.ក នោះទេ។ មាត្រា ៥ ពុំធ្វើការបែកចែករវាង "ការធ្វើមនុស្សឃាត" និង "ការធ្វើទុក្ខបុកម្នេញ" នោះទេ។ ផ្ទុយ

---

[53] Antonio Cassese and Paola Gaeta, *Cassese's International Criminal Law*, Oxford University Press, ឆ្នាំ ២០១៣, ទំព័រ ៩៤ ។

[54] មាត្រា ៦(គ) នៃធម្មនុញ្ញនៃសាលាក្តីយោធាអន្តរជាតិ (ការគូសបញ្ជាក់បន្ថែម)។

[55] Egon Schwelb, 'Crimes Against Humanity', (1946) *23 British Yearbook of International Law*, ទំព័រ ១៩០ ។

មកវិញ អំពើទាំងនេះគ្រាន់តែចាត់ទុកជាបទល្មើសនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតែប៉ុណ្ណោះ។ មាត្រា ៥ ពុំបានបញ្ចូលបទប្បញ្ញត្តិលើកឡើងថា បទល្មើសទាំងឡាយត្រូវប្រព្រឹត្តឡើង "នៅក្នុងពេល ឬ ដែលជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការនៃសាលាក្តី មិនថាបាន ឬ មិនបានរំលោភច្បាប់ក្នុងស្រុកនៃប្រទេសដែលត្រូវបានប្រព្រឹត្តឡើងនោះទេ"។

**ច. យុត្តិសាស្ត្រនៃសាលាក្តី ICTY ដែលរួមបញ្ចូល *យុទ្ធជនដែលបោះបង់ចោលការប្រយុទ្ធ* ថាអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនឆ្លុះបញ្ចាំងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលពាក់ព័ន្ធនោះទេ**

35. សារណាអ្នកមិនមែនជាភាគីជាច្រើនបានសំអាងលើយុត្តិសាស្ត្រនៃសាលាក្តី ICTY ក្នុងការលើកទឡ្ហីករណ៍ថា ប្រជាជនស៊ីវិលដ៏ច្រើនអាចបញ្ចូលជាយុទ្ធជន*ដែលបោះបង់ចោលការប្រយុទ្ធ*យោងតាមគោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[56]។

36. ដូចបានអះអាងនៅក្នុងសារណារួចហើយ ស.ច.ស ត្រូវមានការប្រុងប្រយ័ត្ននៅពេលពិចារណាយុត្តិសាស្ត្រនៃសាលាក្តី ICTY[57]។ សេចក្តីសម្រេចរបស់សាលាក្តី ICTY ធ្វើឡើងក្រោយអំឡុងពេលពាក់ព័ន្ធចំនួនពីរទសវត្សរ៍ អាស្រ័យហេតុនេះ វាពុំទំនងឆ្លុះបញ្ចាំងត្រឹមត្រូវអំពីស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលពាក់ព័ន្ធនោះឡើយ។

37. ម្យ៉ាងវិញទៀត ប្រសិនបើមានវិមតិសង្ស័យទាក់ទងនឹងការបកស្រាយត្រឹមត្រូវលើ "ប្រជាជនស៊ីវិល" ស្របតាមគោលការណ៍នៃ*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ(in dubio pro reo)* វិមតិសង្ស័យទាំងនេះត្រូវបកស្រាយជាប្រយោជន៍ដល់ជនត្រូវចោទនៅក្នុងសំណុំរឿង ០០៣ និង ០០៤[58]។

**ឆ. *អ្នកមិនមែនជាភាគីមានកំហុសដោយសារបានធ្វើសារណាទាក់ទងនឹងអំណះអំណាងអង្គហេតុនៅក្នុងសំណុំរឿង ០០៣ ឬ ០០៤***

---

[56] សូមមើលឯកសារ D306/8 ឯកសារ D306/9 ឯកសារ D306/11។

[57] សារណា, កថាខណ្ឌ ៣០។

[58] សំណុំរឿង ០០២ *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់* ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E50/3/1/4, កថាខណ្ឌ ៣១។ គោលការណ៍នៃ*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ*ក៏ឃើញមានចែងនៅក្នុងមាត្រា ៣៨ នៅក្នុងធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

38. វិសាលភាពនៃសំណើសុំមានលក្ខណៈច្បាស់លាស់ ហើយកម្រិតឲ្យ*អ្នកមិនមែនជាភាគី*ធ្វើសារណាផ្លូវច្បាប់លើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[59]។ ទោះបីជាយ៉ាងនេះក្តី សារណាអ្នកមិនមែនជាភាគីមួយចំនួនធ្វើសេចក្តីសន្និដ្ឋានទាក់ទងនឹងអំណះអំណាងអង្គហេតុនៃសំណុំរឿង ០០៣ និង ០០៤[60]។ ឯកសារ D306/13 លើកឡើងថា៖

> យោធាដែលខ្មែរក្រហមបានសម្លាប់អាចមិនមានឋានៈជាអ្នកបាត់បង់សមត្ថភាពប្រយុទ្ធ(hors de combat)តាមទំនៀមទម្លាប់ធម្មតាទេ ប៉ុន្តែមានភាពស្រដៀងគ្នានេះច្រើន។ យោធាទាំងនេះមិនបានប្រឆាំងនឹងរបបខ្លួនឯងដែលត្រូវសម្លាប់ពួកគាត់ដោយសារមូលហេតុប្រឆាំងបែបនេះ ហើយពួកគាត់ក៏មិនបានប៉ុនប៉ងប្រយុទ្ធ ឬ បង្កើតការបះបោលប្រឆាំងនឹងខ្មែរក្រហមដែរ។ ពួកគាត់គឺជាអ្នកនៅក្រោមការសម្រេចរបស់អ្នកដែលចាប់ខ្លួនពួកគាត់ដែរ។ ជាងនេះទៀត យោធាដែលគេសម្លាប់គឺមានសមាសភាពពូជសាសន៍ផ្សេងគ្នា។ ក្រោយសង្គ្រាមស៊ីវិលពួកគាត់បានក្លាយជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់ខ្មែរក្រហមនៅពេលដែលរបបនេះចាប់ផ្តើមគ្រប់គ្រងរដ្ឋ ហេតុនេះពួកគាត់ "ទទួលដំណែល" ជាកងទ័ព ដូច្នេះធ្វើឲ្យយោធាទាំងនេះកាន់តែក្លាយជាឈ្លើយសឹកទៀត[61]។

39. *អ្នកមិនមែនជាភាគី*មិនគួរធ្វើការសន្មតទាក់ទងនឹងអង្គហេតុនៅក្នុងរឿងក្តីដែលកំពុងស្ថិតនៅក្រោមកិច្ចស៊ើបសួរនៅឡើយ។ លើសពីនេះ ទង្វើករណ៍បែបនេះនាំឲ្យបង្កើតជានិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានសម្របឲ្យត្រូវទៅតាមអង្គហេតុដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០៣ និង ០០៤។ ករណីនេះបានបង្ហាញបន្ថែមនៅក្នុងឯកសារ D306/11 ដែលបង្កើតលទ្ធភាពនៃការដកចេញនូវបុគ្គលិកយោធានៃរដ្ឋខ្លួនជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាបញ្ហាមួយដោយបានលើកឡើងថា "ដំណោះស្រាយដោយផ្អែកលើច្បាប់ទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ គឺត្រូវចាត់ទុកថា សមាជិកនៃកងកម្លាំងប្រដាប់អាវុធគឺជាជនស៊ីវិលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ លើកលែងតែពេលដែលគេចូលរួមផ្ទាល់នៅក្នុងចន្លោះនោះ"[62]។ ការបង្កើតនិយមន័យនៃ "ប្រជាជនស៊ីវិល" ឲ្យទៅជាដំណោះស្រាយចំពោះបញ្ហាអង្គ

---

[59] សំណើសុំ កថាខណ្ឌ ១២ និង ១៤។

[60] សូមមើលឯកសារ D306/11 ឯកសារ D306/12 និងឯកសារ D306/13។

[61] ឯកសារ D306/13 ទំព័រ ៥។

[62] ឯកសារ D306/11 កថាខណ្ឌ ២១។

ហេតុជាក់លាក់ណាមួយនៅក្នុងរបៀបនេះនឹងនាំឲ្យបង្កើតនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយដែលត្រូវបានបំភ្លៃង និងមិនត្រឹមត្រូវ។

សូមលោកចៅក្រមមេត្តាទទួលយកចម្លើយតបរួមនេះដោយក្តីគោរព។

____________________ ________________________

សូ មូស្សេន្នី Suzana TOMANOVIĆ

សហមេធាវីការពារក្តីលោក យឹម ទិត្យ

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៦